Free

សារព័ត៌មាន ខ្មែរផុស ស.រ.អា

KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

REMEDIUM PHARMACY
ឱសថស្ថានរ៉ឺមីឌៀម
2 Vinal Square. North Chelmsford, MA 01863
ជាឱសថស្ថានបំរើការគ្រប់យ៉ាងដល់អ្នក
• ផ្ទេរឬផ្លាស់ប្តូរសេវាកម្ម • ការវេចខ្ចប់ឱសថ • ការលាយផ្សំឱសថ
• បញ្ជូនឱសថដល់ផ្ទះដោយឥតគិតថ្លៃ • ជួយធ្វើសំបុត្រទិញថ្នាំ • ផ្លាស់ប្តូរយោបល់ដោយរាក់ទាក់
ឱសថស្ថានយើងខ្ញុំនិយាយភាសាខ្មែរ
FREE daily delivery | Blisterpack Packaging | Compounding Medication
Friendly consultations | Easy Transfers
Tel: 978-251-7070 | Fax: 978-251-7071

Cambodia Daily
Cambodian Politic

## US POLITICIAN IN CAMBODIAN FRAUD CASE COMMITS SUICIDE

**by KhuonNarim | September 12, 2016**

A New York state assemblyman who was among the defendants in a high-profile fraud case at the Phnom Penh Municipal Court fatally shot himself on Friday in a graveyard in Rochester, part of his district in upstate New York.

William Nojay, 59, also a radio talk show host, attorney, entrepreneur and father of three, was among four men sued by a Phnom Penh dentist for fraud after she invested $1 million in an agricultural firm that never began operations.

William Nojay addresses the New York state compensation committee in an undated photograph posted to his official website.

The other defendants are Sichan Siv, a former U.S. ambassador to the U.N.; Richer San, a prominent Cambodian-

**Continued to Page 10**

# ក្រុងខ្មែរឡូវែលសម្ពោធន៍រូបចម្លាក់ព្រហ្មបាយ័ន

**ដោយខ្មែរផុសស.រ.អា.**

រូបចម្លាក់"ព្រហ្មបាយ័ន"គំរូចម្លងពីប្រាសាទព្រហ្មបាយ័ននៅសៀមរាប, ធ្វើពីថ្មភក់ Sand stone ប្រភពថ្មភ្នំខេត្តសៀមរាប, ឆ្លាក់ដោយវិចិត្រករ"ម៉ៅ ម៉ូវ"នៃក្រុមហ៊ុនសិល្បៈខ្មែរបាន

**តទៅទំព័រទី ១៨**



អ្នកស្រីប្រធានក្រុងខ្មែរឡូវែល ផល្លី ពង្សលក្ខិណា សាធុកា និងគ្រួសារ នៅថ្ងៃតម្លើងរូបចម្លាក់ព្រហ្មបាយ័ន

# ស្ថានភាពប្តូរបន្ទាប់ពីជជែលទល់មុខទីមួយៈ ហីឡារី គ្លីងតុន នឹង ឌណល ត្រម

បេក្ខជនប្រធានាធិបតីអាមេរិកាំងបានធ្វើការជជែកទល់មុខជាលើកដំបូងនៅចំពោះមុខក្រុមអ្នកកាសែតធំៗ កាលពីថ្ងៃ២៦កញ្ញា ២០១៦ វេលាម៉ោង ៩យប់។ មកទល់ពេលនេះ បេក្ខជនទាំងពីរមិនមានប្រជាប្រិយភាពទេ តែបន្ទាប់ពី ជជែកទល់មុខទី១ ការស្ទង់មតិ CNN ភ្លាមៗ លទ្ធផលលើកិច្ចការបរទេសៈ ហ៊ីឡារី ៦២% ឌុណល ២៧ -លទ្ធផលលើសេដ្ឋកិច្ចៈ ហ៊ីឡារី ៥៤% ឌុណល ៤៥% ។ នៅមានការជជែកទល់មុខរបៀបនេះ២ដងទៀត នៅមុនពេលបោះឆ្នោតថ្ងៃទី៨ វិច្ឆិកា៕




ឌុល ណាល់ត្រម និងហ៊ីឡារី គ្លិនតុន

CENTURY PHARMACY & OPTICAL
937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554
ឱសថស្ថានសេនជូរី :
យើងជាអ្នកបំរើលោកអ្នកយ៉ាងប្រសើរ!


▸ ផ្តល់សេវាដល់ទីលំនៅ
▸ ខ្ចប់ឱសថតាមបំណង
▸ ជាឱសថស្ថានដែលលោកអ្នកអាចជឿជាក់ក្នុងចិត្ត
937 Gorham St Lowell, MA, 01852
លេខទូរស័ព្ទ 978-455-6554 / លេខហ្វាក់ 978-455-9476

មេធាវី លួយហាស្កែល
Attorney Louis S. Haskell
978-459-8359
16 Pine Street - Lowell, MA 01851
www.attorneyhaskell.com

របួសរាងកាយ គ្រោះថ្នាក់ចរាចរ
PERSONAL INJURY AUTO ACCIDENTS
យើងនិយាយភាសាខ្មែរ.ឡាវ.ថៃ
អាចណាត់ជួបពេលល្ងាចក៏បាន
មានកន្លែងចតរថយន្តឥតចេញថ្លៃ
មានអាជ្ញាប័ណ្ណនៅរដ្ឋ MA និង NH
បំរើសហគមន៍ខ្មែរតាំងពីឆ្នាំ១៩៨៧
We Speak Khmer, Lao, Thai
Evening Appointments Available
Free Parking
Licensed in MA & NH
Serving the Cambodian Community since 1987

# បានទទួលមួយ ឬទាំងពីរក្នុងចំណោមប័ណ្ណទាំងនេះ?

# ទទួលយកបន្ថែម។




ទទួលយកអត្ថប្រយោជន៍ច្រើនជាងអ្វីដែលអ្នកបច្ចុប្បន្នកំពុងទទួលបានពី Original Medicare និង MassHealth ជាមួយគម្រោង **UnitedHealthcare® Senior Care Options (HMO SNP)**។ វារួមបញ្ចូលគ្នានូវវេជ្ជបណ្ឌិតរបស់អ្នក មន្ទីពេទ្យ និងការគ្របដណ្ដប់ឱសថមានវេជ្ជបញ្ជាគ្រប់ទៅក្នុងគម្រោងមួយ គឺសម្រាប់ បុព្វលាភរ៉ាប់រងគម្រោង **$0**។**

## អត្ថប្រយោជន៍បន្ថែមអាចរួមមាន៖

**ឱសថមានវេជ្ជបញ្ជា**
រាប់ពាន់នៃឱសថអាចប្រើបាន។

**ការគ្របដណ្ដប់លើទន្តសាស្ត្រ**
សហចំណាយ **$0** សម្រាប់ការដាក់ធ្មេញ និងក្រាសធ្មេញពាក់។

**ជំនួយលើមធ្យោបាយធ្វើដំណើរ**
សហចំណាយ **$0**សម្រាប់ការជិះទៅជួបវេជ្ជបណ្ឌិតតាមការណាត់។

**កាតាឡុកផលិតផលសុខភាព**
រហូតដល់ទៅ **$160** ក្នុងឥណទានប្រចាំឆ្នាំដើម្បីទិញ ផលិតផលសុខភាពពីកាតាឡុករបស់យើង។

**ទូរស័ព្ទមកថ្ងៃនេះដើម្បីចុះឈ្មោះ ឬទទួលបានចម្លើយទៅនឹងសំណួររបស់អ្នក។**



BOPHA PEOU
Licensed Sales Agent # 2016784
**Contact # (978) 221-9970, TTY 711**
[8 a.m. – 8 p.m. local time, 7 days a week]

**UHCCommunityPlan.com/MA**

UnitedHealthcare
Community Plan

UnitedHealthcare SCO គឺជាគម្រោងថែទាំសុខភាពដែលមានការសម្របសម្រួលមួយ ដែលមានកិច្ចសន្យាជាមួយ Medicare និងជាប់កិច្ចសន្យាជាមួយកម្មវិធី Commonwealth of Massachusetts Medicaid ។ ការចុះឈ្មោះនៅក្នុងគម្រោងគឺផ្អែកទៅលើការបន្តកិច្ចសន្យាជាថ្មីរបស់គម្រោងជាមួយ Medicare ។ គម្រោងនេះគឺជាកម្មវិធីស្ម័គ្រចិត្ត ដែលអាចរកបានសម្រាប់អ្នកដែលមានវ័យចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ MassHealth Standard និង Original Medicare ។ ប្រសិនបើលោកអ្នកមាន MassHealth Standard ប៉ុន្តែលោកអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាន Original Medicare លោកអ្នកនៅតែមានសិទ្ធិចុះឈ្មោះក្នុងគម្រោង MassHealth Senior Care Option និងទទួលបានអត្ថប្រយោជន៍ MassHealth ទាំងអស់របស់លោកអ្នកតាមរយៈកម្មវិធី SCO របស់យើង។ ព័ត៌មាននេះគឺមិនមែនជាការពិពណ៌នាពេញលេញអំពីអត្ថប្រយោជន៍នោះទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកគម្រោង។ ការកំណត់សហចំណាយ និងការដាក់កំហិតនានាអាចត្រូវអនុវត្ត។ អត្ថប្រយោជន៍ បុព្វលាភរ៉ាប់រង និង/ឬសហចំណាយ/សហធានារ៉ាប់រងអាចផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ បុព្វលាភរ៉ាប់រង សហចំណាយ សហធានារ៉ាប់រង និង ថ្លៃបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យ អាចប្រែប្រួលតាមកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទាក់ទងមកគម្រោងសម្រាប់ព័ត៌មានលំអិតបន្ថែមទៀត។ អ្នកចុះឈ្មោះមិនតម្រូវឲ្យបង់ប្រាក់ពីហោប៉ៅឡើយ។

H2226_150915_093829 Accepted
UHCSCO_150915_093829

CST10056_ H2226-001

# អាគារក្រសួងយុត្តិធម៌ថ្មីនឹងប្តូរមុខមាត់ឡូវែល

**ដោយខ្មែរផុសស.រ.អា**

មន្ត្រីសំខាន់ៗនៃតំបន់ឡូវែលនឹងមកពីបូស្តុន រដ្ឋម៉ាសាឈូសិត ប្រមាណ៣០០នាក់ បានមកជួបជុំគ្នានៅទីលានដ៏ទូលាយមួយនៅ"កាណាល់ហាមីលតុន"ដើម្បីសម្ពោធន៏ការដ្ឋានថ្មីមួយដែលមានកំពស់ខ្ពស់ស្កឹមស្កៃដែលនឹងក្លាយទៅជាក្រសួងយុត្តិធម្ម នាប្រមាណ៣ឆ្នាំខាងមុខទៀតនេះ។

ក្រោមអធិបតីភាពនៃលោកអភិបាលរដ្ឋម៉ាសាឈូសិត ឆលី បេគ័រ នឹងលោកស្រីអភិបាលរងលោកស្រី ការិន ផលីតូ ពិធីសម្ពោធមួយនេះឱ្យសញ្ញាដល់សាធារណជនថា"អាគាថ្មីស្រឡាងមួយនឹងផុសឡើង"នៅចំកន្លែងដែលមនុស្សសំខាន់ៗក្នុងសេចក្តីថ្លៃថ្នូរនៃមនុស្ស -ព្រឹទ្ធសមាជិក អាលីន ឌូណូហ្យូនិយាយថា: ... ថម គូលដើរីដ ណើង គ្វើល តំណាងរដ្ឋនៅតំបន់ឡូវែលនិយាយថា: ជាការមើលឃើញសេចក្តីត្រូវការចាំបាច់ ហើយរកលុយមកឱ្យសហគមន៏, តំណាងរដ្ឋសង្កាត់លេខ ១៨វ៉ាឌី ម៉ម និយាយថា: រីករាយដោយបានចូលឈ្មោះក្នុងគម្រោងដ៏ធំនេះនឹងគេដែរ -លោក





អភិបាលរដ្ឋ បេគី (ក្រវ៉ាត់កខៀវ) និងថ្នាក់ដឹកនាំក្រុងឡូវែលសម្ពោធការដ្ឋាននៅឡូវែល

ក្រុងកំពុងមកជួបជុំគ្នាថ្ងៃ២២កញ្ញានេះ នាកណ្តាលក្រុងឡូវែល ហើយដែលមុខមាត់ នៃទីក្រុងឡូវែលដ៏"តូច"មួយនេះក៏កំពុងប្រែក្លាយទៅជាតំបន់ដ៏"ធំ"បំផុតមួយម្តងបន្តិចៗពីថ្ងៃនេះទៅហើយដែរ។

អេដ កេណ្ណីឌី អភិបាលក្រុងឡូវែលនិយាយពីអរគុណអភិបាលរដ្ឋដែលបាននាំថវិការមកឱ្យឡូវែល -ចុងបញ្ចប់ ឆាលី បេគី និយាយថា:

លោកព្រមបញ្ចេញថវិការក៏ដោយសារទាំងអស់បានមូលមាត់គ្នានិយាយភាសាតែមួយ។






សន្ទរកថា លោកអភិបាលក្រុងឡូវែល អេដ កេណីឌី

តាំងពីចៅក្រមថ្នាក់កំពូល-ថ្នាក់កណ្តាល-ថ្នាក់ទាបតាំងពីមេធាវីដ៏ល្បីល្បាញ រហូតដល់មេប៉ូលិស-វិស្វករ-ស្ថាប័ត្យករ ចុងក្រោយបង្អស់មន្ត្រីសាលាក្រុងដែលជាអ្នកទទួលផល់ពីគម្រោងមានតម្លៃ២០០លានមួយនេះ បានដកដង្ហើមបន្ធូរចិត្តដោយការប្រឹងប្រែងបង្កើតអាគានេះ តាំងពី១៥ឆ្នាំមកហើយ បានមកដល់ពន្លឺនៃទីបញ្ចប់បាន។

នៅទីនោះគេបានដឹងពីតួរនាទីនៃអ្នកទទួលខុសត្រូវគ្រប់ស្រទាប់ ដើម្បីធានាគោលការនៃ"ការរួមរស់ដោយសន្តិភាព នៅក្នុងគម្រោងតែមួយ" មន្ត្រីតុលាការផូល្លា ខារី និយាយថា: "សេរីភាពរបស់ពលរដ្ឋត្រូវភ្ជាប់ជាមួយនឹងការទទួលខុសត្រូវ" -ចៅក្រម វ៉ាល់ គ្លេននិយាយថា: យុត្តិធម៌ គឺជា

បឋមសីលាបានត្រូវបញ្ចុះនាប្រមាណម៉ោង៣រសៀល ការដ្ឋានដ៏ធំមួយបានចាប់ផ្តើមភាពរីករាយបានផុសនៅលើទឹកមុខនៃគ្រប់មន្ត្រីដែលមកចូលរួមពិធីសម្ពោធនេះ។ គេមិនបាច់ឆ្ងល់ពីការអបអរសាទររបស់ប្រជាពលរដ្ឋរួមរស់នៅក្នុងតំបន់ដែលនឹងទាញយកភាគផលពីការមកឈរជើងរបស់ក្រសួងយុត្តិធម៌ជាមួយនឹងបុគ្គលិកប្រមាណ៨០០នាក់ថ្មី នៅចន្លោះ "ក្រុងខ្មែរ" នឹងពេទ្យ"មេត្តា" ពីព្រោះសម្មិទ្ធិនេះនឹងនាំមកនូវ "លំអថ្មីនៅក្នុងទីក្រុងចាស់ឆ្នាំ" នាំមកនូវទេសចរចូលមកទីក្រុងដែលមានវប្បធម៌ចម្រុះ ជាពិសេសនាំមកនូវសេចក្តីសង្ឃឹមថា "អភិវឌ្ឍន៏" កំពុងតែកើនកើរីតបន្ថែមនៅក្នុងតំបន់នេះហើយ៕

# ជីវប្រវត្តិនឹងទស្សនៈសង្ខេបរបស់ លោក រ៉ាឌី ម៉ម

**ដោយខ្មែរផុសស.រ.អា.**

លោក រ៉ាឌី ម៉ម បច្ចុប្បន្នជាសមាជិកតំណាងរដ្ឋសង្កាត់១៨ លោកឈរឈ្មោះជាបេក្ខជនគណបក្ស "ប្រជាធិបតេយ្យ"សាជាថ្មីប្រជែងនៅក្នុងការបោះឆ្នោតជុំទី២នេះដោយលោក ខេមរា ខៃ មកពីគណបក្ស "សាធារណរដ្ឋ" ។

លោក រ៉ាឌី ម៉ម អាយុ៤៦ឆ្នាំ មានភរិយានឹងកូន៤នាក់: ស្រី២ប្រុស២ ។ លោកមកដល់សហរដ្ឋឆ្នាំ១៩៨២ ក្នុងនាមជាជនភៀសខ្លួន ដំបូងនៅរដ្ឋ"មេនីសូតា"- ឆ្នាំ១៩៨៤ ទើបមកដល់ "ឡូវែល" រដ្ឋម៉ាសាឈូសិតរៀនសូត្រនៅសាលាសាធារណរួចទៅបន្តវិជ្ជានៅសាលាបច្ចេកទេសខាងចាប់សរសៃនឹងរៀននៅមហាវិទ្យាល័យ “Middlesex Community College” ។ លោកបានទៅរៀន



ជំនាញបូរាណខាងចាប់សរសៃ -មានជំនាញជាអ្នកថតរូបឯកទេស ហើយធ្លាប់ធ្វើការនៅមន្ទីរពេទ្យផង ។

លោកជាសកម្មជនសម្រាប់សហគមន៍ខ្មែរចំនួន២៥ឆ្នាំ តាំងពីជួយរៀបចំពិធីបុណ្យអុំទូកដោយស្ម័គ្រចិត្ត រហូតដល់បានកេរឈ្មោះល្បីល្បាញដល់សង្គមស្ម័គ្រចិត្តជួយពិធីបុណ្យចូលឆ្នាំខ្មែរដែលប្រព្រឹត្តទៅនៅរៀនរាល់ឆ្នាំ...ក្នុងនោះមានទាំងជាសមាជិកគណកម្មកានាយក"Boys & Gils Club"គណកម្មការគ្រប់គ្រងនៅពេទ្យ"Saint Memorial Medical Center" នៅសមាគមខ្មែរនៅខាងកិច្ចការវប្បធម៌ ។

តើលោកបានធ្វើអ្វីខ្លះដែលសំខាន់ក្នុងអាណត្តិរបស់លោក? សម្រាប់បងប្អូនណាដែលមិនដឹងក្នុងតួនាទីជា"ដំណាងរាស្ត្រ"ខ្ញុំមានភារៈកិច្ច រកលុយពី"បូស្តុន"មកជួយថវិការសម្រាប់សង្កាត់លេខ១៨ក្រុងឡូវែលយើងនេះ។ នៅ "ខពលស្ត្រែ" ខ្ញុំរកបាន៩៥ម៉ឺនសម្រាប់កែរលំអផ្លូវនៅកន្លែងនោះឥឡូវនេះកន្លែងនោះធ្វើជូនបងប្អូនបានស្អាតហើយ ។ ខ្ញុំបានធ្វើនៅកន្លែងឧទ្យាន "ខាឡឺរីផាក" ឱ្យទោះជាថ្មីឡើងវិញ ចូលរួមជាមួយសាលាក្រុងចំណាយអស់៨៥ពាន់ដុល្លា -ជួសជុលកន្លែងលេងបាល់"បារែតនឹងខនរយ" រួមកម្លាំងជាមួយសាលាក្រុងនឹងធ្វើហើយសព្វគ្រប់នៅថ្ងៃ១តុលានេះហើយ ហ្នឹងចំណាយអស់៥៥ពាន់ទៀត។ ខ្ញុំបានជួយសុំថវិការសម្រាប់ការអប់រំ -សុំថវិកាសម្រាប់អប់រំការពារសន្តិសុខ(សុំបានហើយ) -ហើយ



ដើម្បីផ្តើមការដ្ឋានក្រសួងយុត្តិធមិបាននោះ យើងបានរកលុយមកចំណាយបាន៤,៧លានដុល្លាមកធ្វើការនៅ"កាណាល់ហាមិលតុន"រួចជាស្រេចទៀត។ លោក រ៉ាឌី បន្តថា "ខ្ញុំរវល់សម្បើមណាស់ តែរីករាយនឹងធ្វើការបានផល់ជូនសហគមន៍យើងសហគមន៍នោះ សូមឱ្យយល់ គឺខ្ញុំត្រូវធ្វើការជូនសហគមន៍ទាំងមូលដែលមានជាតិសាសន៍ចំរុះគ្នា" ។

តើអ្វីទៀតដែលលោកនៅមិនទាន់បានធ្វើហើយចង់បំពេញនៅអាណត្តិក្រោយ? ការងារសម្រាប់ជួយសហគមន៍ណៅមានច្រើនទៀត ហើយក៏សំខាន់ណាស់ដែរ តែដែលខ្ញុំចាប់អារម្មណ៍ខ្លាំងនោះគឺស្ពាន"រូក"ដែលជាស្ពានបណ្តោះអាសន្នចំនួនជាង៣០ឆ្នាំមកហើយ ទទួលបានតែធម្ងន់បានតែ៤៥តោនប៉ុណ្ណោះ មាន "ផ្លូវមួយខ្សែទៅមួយខ្សែមក" បើមានគ្រោះថ្នាក់អីមិនអាចសង្គ្រោះគ្នាបានទេ ហេតុដូចនេះហើយបានជាចាំបាច់ណាស់ដែលស្ពាននេះត្រូវតែធ្វើឡើងជាបន្ទាន់។ ភាពបន្ទាន់នេះ បន្ថែមដោយសារសំខាន់នៃស្ពាននេះគឺជាចំណុចប្រជុំគ្នានៃតំបន់ធំ៧៣-៤មកចម្រុះគ្នាហើយឡូវែលខ្លួនឯងក៏ក្លាយជាធំទៅហើយដែរតាំងពីប៉ុន្មានឆ្នាំចុងក្រោយនេះ ចរាចរក៏កាន់តែខ្លាំងកាន់តែស្ទះផ្លូវក៏កាន់តែខ្លាំងដោយតំបន់ក្បែរៗនោះមានអភិវឌ្ឍន៏ ហើយពេទ្យធំក៏នៅត្រើយម្ខាងផ្ទុយពីត្រើយក្រុងធំដែលប្រជាជនជាច្រើនរស់នៅ ម្ល៉ោះហើយប្រជាជនប្រើស្ពាននោះខ្លាំងណាស់ ។

ចំពោះអ្នកដែលមិនសប្បាយចិត្តដោយលោកបានទៅជួបគួរសមនឹងលោក ហ៊ុន សែន តើ

តទៅទំព័រទី០៧

# ជីវប្រវត្តិនិងទស្សនៈលោក ខេមរា ខៃ បេក្ខជន ដំណាងរដ្ឋសង្កាត់១៨រដ្ឋម៉ាសាឈូសិត

**ដោយខ្មែរផុសស.រ.អា.**

ក្នុងការបោះឆ្នោតជុំទី២ផ្តាច់ព្រ័តថ្ងៃទី៨វិច្ឆិកា ខាងមុខបេក្ខជនខ្មែរ-អាមេរិកាំង២នាក់ប្រកួតគ្នាក្នុងដំណែងតែមួយ។ លោក ខេមរា ខៃ




ជាបេក្ខជនមកពីគណបក្ស"សាធារណរដ្ឋ"ប្រកួតនឹងលោក រ៉ាឌី ម៉ម បច្ចុប្បន្នជាសមាជិកតំណាងរដ្ឋចប់អាណត្តិនៅចុងខែធ្នូខាងមុខ។

ខេមរា ខៃ មានគ្រួសារគិតទៅ១៨ឆ្នាំ ហើយៗមានកូន៣នាក់ប្រុស២ស្រី១បានទាំងចៅម្នាក់ផង ។ មកដល់សហរដ្ឋតាំពីឆ្នាំ ១៩៨២។ មកដល់ដំបូងនៅក្រុង "រីជម៉ុន"នៃរដ្ឋ "វៀជីនា"រៀនសូត្រនៅទីនោះរហូតមកដល់ឆ្នាំ ១៩៨៧ឪពុក (លោកប្រាហ៊ឹម ខៃ) បានសម្រេចនាំគ្រួសារចាកចេញពី"រីចម៉ុន"មកនៅឡូវែលនេះតែម្តង។ នៅបានបន្តិចបន្ទាប់ពីរៀនចប់នៅវិទ្យាល័យឡូវែលក៏ត្រូវចេញមកបន្តការសឹក្សានៅមហាវិទ្យាល័យ "វើម៉ន"រហូតបានអនុបណ្ឌិត"Master Degree"

**១៩៩១-៩៥ រៀននៅសាលាទាហ៊ាន**

១៩៩៦-២០០៤ រៀនមហាវិទ្យាល័យរហូតដល់បានសញ្ញាប័ត្រអនុបណ្ឌិត Master Degree

២០០៦-១៤នាយទាហ៊ាន ជាមេបញ្ជាការរង Deputy Commander, G6 IT

២០០៩-១៤ មានតួរនាទី ជាអនុប្រធានមហាវិទ្យាល័យ Associate AccademicDean

២០១៤ ត្រឡប់មកធ្វើការនៅ "បូស្តុន" ជាអ្នកវិភាគបច្ចេកទេសកុំព្យូទ័រជាឱកាសបានត្រឡប់មកនៅឡូវែលវិញ

អ្វីទៅដែលបណ្តាលលោកចង់ឈរឈ្មោះជាតំណាងរដ្ឋសង្កាត់១៨នេះ?ខ្ញុំឃើញថាបងប្អូនយើងមិនទាន់មានការឧបត្ថម្ភពីអ្នកគ្រប់គ្រងយើងឱ្យបានគ្រប់គ្រាន់នៅឡើយទេ...ពួកគាត់មិនថាខ្មែរឬសាសន៍ណាទេ គេត្រូវការឱ្យតំណាងរាស្ត្រហ្នឹងជួយ តែពួកគាត់ត្រូវការឱ្យអ្នកជួយហ្នឹងមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ជួយគេទៀត ខ្ញុំជឿថា "ខ្ញុំមានភារកិច្ចទៅទាមទារកន្លែងអ្នកធ្វើការសព្វថ្ងៃហ្នឹងមកបំរើបងប្អូនវិញ ទើបមានប្រសិទ្ធភាព"...

ក្នុងករណីដែលលោកជាប់ឆ្នោត តើលោកនឹងធ្វើអ្វីមុនគេ?ខ្ញុំមានការខ្វល់ខ្វាយច្រើនពីអាគានឹងទីលំនៅចាស់ៗរបស់ក្រុងយើងរាប់ទាំងស្ពានចាស់មួយនោះសង់បណ្តោះអាសន្នយូរណាស់ហើយជាង៣០ឆ្នាំហើយ មិនមាននរណាគិតដល់ទេថាត្រូវធ្វើជាបន្ទាន់! ធ្វើស្ពាននេះអស់៥០-៥៥លានតើបានលុយនោះពីណា? អស់លោកតំណាងរាស្ត្រតំបន់យើងហ្នឹងគាត់យល់ថា ធ្វើអាគារឱ្យខាងតុលាការវាសំខាន់ជាងចាយលុយទៅខាងនោះទៅហើយ ធ្វើម្តេចនឹងធ្វើស្ពានចាស់នោះបាន? ម្លោះហើយគេទុករឿងសន្តិសុខក្នុងការប្រើស្ពានចាស់នឹងការលំបាកនឹងបំរើជីវភាពរាល់ថ្ងៃនោះជាបន្ទាប់បន្សំ... ម្យ៉ាងវិញទៀត ជីវភាពរាល់ថ្ងៃរបស់ពលរដ្ឋយើងជាច្រើនបានប្រាក់ខែមិនបាន២ម៉ឺន-២.៥ម៉ឺនជាមធ្យម, ដោយការងារលំបាកហើយចាយ



មិនគ្រាន់ក៏ទៅធ្វើការទី២ទី៣ទៀត ខ្ញុំគិតថា អានេះមកពីចំណេះវាតិចតម្រូវឱ្យយើងគិតគូរឱ្យពួកគាត់ទៅរៀនសូត្របន្ថែម ដើម្បីទៅធ្វើការឱ្យបានប្រាក់ខែច្រើនចាយគ្រប់គ្រាន់ ហើយអាចថែរសុខភាពបានប្រសើរផង...នេះមកពីគាត់មិនដឹងទៅណា? ខ្ញុំមានសមត្ថភាពអាចជួយពលរដ្ឋរបស់យើងបាន...

ហេតុអ្វីទៅដែលនាំឱ្យលោកប្រកាន់យកគណបក្ស"សាធារណរដ្ឋ"ជាមាគ៌ានយោបាយរបស់លោក? មែនទែនទៅឈ្មោះគណបក្សមិនសំខាន់ទេ តែដែលខ្ញុំសង្កេតឃើញមក ថាគណបក្សសាធារណរដ្ឋគេគិតពីគុណភាពមនុស្សដែលពូកែនោះខ្លាំងណាស់ រីឯគណបក្សប្រជាធិបតេយ្យយល់ដូចគ្នាដែរ តែមិនបានធ្វើគាត់ច្រើននិយាយក្នុងនាមអ្នកក្រ ដូចជាថា "អ្នកមានឱ្យប្រាក់ខែគេតិចបានទៅជាក្រ..." តាមពិតទៅគ្មានអ្នកណាចង់ឱ្យគេក្រទេ តែគេចង់បានមនុស្សមានគុណភាពសម្រាប់យកទៅធ្វើការឱ្យបានផល់ការនិយាយហេតុផល "មិនពិត" របៀបនេះហើយដែលខ្ញុំមិនចូលចិត្ត...ដែលខ្ញុំចូលចិត្តនោះគឺគណបក្សសាធារណរដ្ឋជួយដល់មនុស្សទាំងអស់ឱ្យរីកចំរើនឱ្យអាចរស់បានដោយខ្លួនឯង ដោយមិនចាំបាច់ពឹងកម្លាំងអ្នកដ៏ទៃដូចៗគ្នា ហើយខ្ញុំជាខ្មែរ មើលឃើញច្បាស់ពីបញ្ហាដែលសហគមន៍ខ្មែរយើងមានដែលសហគមន៍ក្រីក្រមាន, គឺចង់ជួយឱ្យបាន

តទៅទំព័រទី ០៧

# តាំងពិព័ណ៌: បន្លែបណ្ដុះនៅឡូវែល
# Mill City Grows Lowell festival

**ដោយ ខ្មែរផុសស.រ.អា**

ការតាំងពិពណ៌របស់"ក្រុមបណ្ដុះបន្លែនៅឡូវែល"កាលពីរសៀលថ្ងៃទី១៨ នៅឡូវែលបាននាំមនុស្សរាប់រយនាក់ឱ្យមកចូលរួមកម្សាន្តនឹងទទួលព័តិមានពីគោលបំណងដ៏ថ្លៃថ្លា នៃការបង្កើនផលដ៏ងាយស្រួលតាមធម្មជាតិ ស្របគ្នានឹងបំណងការបង្កើនសុខភាពបណ្ដាជនដែលរស់នៅក្នុងតំបន់ទៀតផង។

តូបបង្ហាញផលិតផលជាច្រើនប្រមាណ៥0 បានតម្រៀបគ្នានៅជុំវិញទីលានសម្រាប់សម្ដែងសិល្បៈរាងមូលមួយនៅចំកណ្ដាលដែលពីធីករនឹងសិល្បៈករឡើងមកសម្ដែងស្នាដៃជូនទស្សនិកជនដែលមានទាំងក្មេងទាំងចាស់មានអ្នកស្ម័គ្រចិត្តរាប់រយមកចូលរួមរីករាយនឹងលទ្ធផលដែលសមាគម "Mill City Grow" បានបំពេញច្រើនឆ្នាំមកហើយ។ ពិធិករបានឱ្យដឹងថា ពិធីនេះបានចាប់កំណើតតាំងពី៤ឆ្នាំមកហើយ ហើយចេះតែរីកធំទៅជារៀងរាល់ឆ្នាំទៅហើយ។

មនុស្សចាស់នឹងជំទង់ដើរកំសាន្តសិក្សាពីសមិទ្ធិផលបណ្ដុះបន្លែតាមធម្មជាតិនឹងសាខានៃបច្ចេកវិជ្ជាដដែល ដែលប្រជាជនអាចចូលរួមចំណែកអភិវឌ្ឍន៍ក្នុងសង្កាត់របស់ខ្លួន...រីឯកុមារទៅកំសាន្តនៅកន្លែង"គូរលើផ្លែល្ពៅ"ឬនៅកន្លែងលេងកីឡា ឬក៏នៅកន្លែង "គូរគំនូរលើផ្ទៃមុខ" ជាមេអំបៅ ជាមុខឆ្មា ជាកណ្ដុរ ជាដើម... ទាំងអស់គ្នាទៅស្រស់ស្រូបអាហារថ្ងៃត្រង់យ៉ាងរីករាយនឹងមិនមានចំណាយប្រាក់ជាមួយនឹងផលិតផលសមាគម មាន"ពីតហ្សា"ក្ដៅ១ ភេសជ្ជៈ នំនែកម្ហូបធ្វើពីបន្លែស្រស់... ។ល។

មានការចែករង្វាក់ជាច្រើនដល់: ផលិតករស្ម័គ្រចិត្តដែលបានផលិតបន្លែច្រើនធុនច្រើនបែបនឹងច្រើន"ផោន"... ដល់អ្នកដែលលើកទឹកចិតដល់ក្រុមកសិករស្ម័គ្រចិត្ត...ដល់អ្នកដែលបានក្លាយទៅជាអ្នកប្រើប្រាស់ផលិតផលដែលខ្លួនធ្លាប់ជាផលិតករ... ។ល។











ការតាំងពិពណ៌សកម្មភាព"ក្រុមបណ្ដុះបន្លែនៅឡូវែល"កំពុងតែមានប្រជាប្រិយភាពដោយសកម្មភាបនេះជាកត្តាមួយដែលនាំឱ្យឡូវែលរឹតតែក្លាយទៅជាតំបន់"ងាយស្រួលរស់នៅ"កាន់តែប្រាកដឡើង ៕



# CENTURY PHARMACY & OPTICAL

937 Gorham St ALL MAJOR INSURANCES ACCEPTED Tel: 978-455-6554

យើងជា
ឱសថ
ស្ថានមួយ
ដែលអាចផ្តល់
ភាពជឿជាក់
ដល់គ្រួសារ
លោកអ្នក




យើងខ្ញុំ
សូមជូនពរ
មហាប្រសើរ
ដល់លោក
អ្នក

- យើងខ្ញុំមានផ្តល់សេវាបំរើការជូនឱសថដល់ទីលំនៅ ។
- យើងខ្ញុំទទួលកាតម៉ាសហ៊ែល, និងកាតធានារ៉ាប់រង សុខភាពផ្សេងៗទៀត
- សេវាបំរើការល្អ,អតិថិជនមានភាពជឿជាក់ ។
- យកចិត្តទុកដាក់លើបញ្ហាផ្ទាល់ខ្លួននៃអតិថិជនរាល់រូប ។
- វេចខ្ចប់ឱសថសមតាមបំណងនៃអតិថិជន ។
- មានផលិតកម្មពិសេសរបស់អូធីស៊ីជារៀងរាល់ខែ ។
- យើងខ្ញុំទទួលការផ្សំថ្នាំតាមបទបញ្ជាជូនដល់អស់លោកអ្នក ។

ជាឱសថស្ថានមួយអាចផ្តល់ភាពជឿជាក់ដល់គ្រួសារអ្នក ។






យើងខ្ញុំនិយាយភាសាខ្មែរ ។

លេខទូរស័ព្ទ 978-455-6554

លេខហ្វាក់ 978-455-9476

937 Gorham St Lowell, MA, 01852

# ស្បៀងហៃទីក្រុងធំរបស់ចិនកុម្មុយនិស្ត

ទំព័រទេសចរណ៍

**ដោយ ពិន សំខុន** **តពីលេខមុន**

"ប្រព័ន្ធអាំងទែណែត"ពីសណ្ឋាគារទៅជាមួយបុគ្គលិកនៅកម្ពុជានឹងនៅឡូវែល...ពេលនោះទើបយើងដឹងថា នៅប្រទេសចិនមិនមាន "ប្រព័ន្ធគូហ្គោល"នឹងប្រព័ន្ធ"ហ្វេសប៊ុក"ដ៏ល្បីល្បាញនៅក្នុងពិភពលោកនោះទេ ដែលធ្វើឱ្យយើងងាកមករកប្រើ"ប្រព័ន្ធយ៉ាហ៊ូ"ទៅវិញ ដែលទំហំទំនាក់ទំនងតូចជាងតែនៅប្រើបានក្នុងប្រទេសចិន។ ជាមួយគ្នានោះយើងដឹងដែរថា រូបភាពនយោបាយ ដូចជាការប្រកួតប្រជែងនៅសេដ្ឋវិមានសហរដ្ឋអាមេរិក បានត្រូវរាំងស្ទះមិនឱ្យចេញផ្សព្វផ្សាយបានឃើញជាសាធារណនោះទេ...ផ្ទុយទៅវិញ ព័ត៌មានស្តីពីការបរាជ័យដែល "អាស៊ាន" មិនបានចេញសេចក្តីថ្លែងការណ៍រួមនៅកិច្ចប្រជុំ "វៀងចាន" ប្រឆាំងវត្តមានប្រទេសចិននៅដែនសមុទ្រខាងត្បូងបានត្រូវបំពងយ៉ាងខ្ទរខ្ទារទាំងក្នុងទូរទស្សន៍នឹងក្នុងកាសែតជាភាសាអង់គ្លេស ៕ យើងមិនបានដឹងថានៅក្នុងកាសែតជាភាសាចិននិយាយពីអ្វីទេពីព្រោះមិនចេះចិន) ។

សណ្ឋាគារ"រីណេសង់"ស្ថិតនៅកណ្តាលសង្កាត់ថ្មីដើងមួយដែលមានសំណង់ប្រវត្តិសាស្ត្រជាអតីតវិហារបូរាណដ៏ធំដែលគេប្រើជាហាងលក់ដូរឥវ៉ាន់នានា។ ទីនោះមានប្រជាប្រិយណាស់មានមនុស្សទៅមកច្រើនណែនណាន់តាន់តាប់ទិញរបស់ក៏ច្រើន ពីព្រោះជាទូទៅគេលក់របស់ដែលមានតម្លៃទាប... រីឯកន្លែងប្រណិតមានលក់របស់តម្លៃខ្ពស់មានមនុស្សដើរច្រើនដែរ តែមិនសូវមានអ្នកទិញទេ-ហាងលក់គ្រឿងអលង្កាមានច្រើនហួសការស្មាននោះ ក៏មិនសូវឃើញមានភ្ញៀវដែរ។

នៅពេលដើរកំសាន្តតាមផ្លូវដ៏ធំទូលាយជាច្រើនខ្វាត់ខ្វែងព័ទ្ធជុំវិញមហាអាគាធំៗខ្ពស់ៗប្រកបដោយរូបរាងទំនើបៗ ប៊ុណ្ណារ៉ូ ឧទ្ទានជាភាសាខ្មែរថា"ទីនេះដូចផ្ទះយើងនៅអាមេរិកាដែរ", នេះជាការពិត ព្រោះធ្វើឱ្យយើងនឹកទៅដល់ទីក្រុងញូយ៉កនៃសហរដ្ឋអាមេរិក តែទីក្រុងនេះស្អាតជាងគ្មានកន្លែងគគ្រិចក្រខ្វក់ទេ គ្មានរុយឬមូសមករំខានមនុស្សឬម្ហូបទេ -ប៊ុណ្ណារ៉ូ មកលើកនេះ ធ្វើអត្ថាធិប្បាយជាភាសាខ្មែរបានច្រើននៅឯប្រទេសចិនកុម្មុយនិស្តដោយសារកាលពីមកដល់ស្រុកខ្មែរក៏និយាយខ្មែរ,ទៅដល់ស្រុកយួនទៀត **តទៅទំព័រទី ១៤**





សណ្ឋាគាររីណេសង់






Multiple Policies.
One agent.

I can help you save time & money.
One agent for all your insurance needs saves time. And Allstate's multi-policy discounts are an easy way to save money. For affordable protection for your car, home, boat, motorcycle and more, call me first.



Chennara Kim
The Wicks Insurance Group, Inc.
978-710-7040
83 Parkhurst Road
Chelmsford, MA 01824
chennarakim@allstate.com

Allstate. You're in good hands.
Auto Home Life Retirement

យើងខ្ញុំអាចនិយាយភាសាខ្មែរ

Insurance and discounts subject to terms, conditions and availability. Allstate Insurance Co., Allstate Vehicle and Property Insurance Co. Northbrook, IL. © 2016 Allstate Insurance Co.

174603


## តមកទំព័រទី ០៤ ជីវប្រវត្តិ និងទស្សនៈលោក ខេមរា ខៃ

ផ្លូវស្រោល ហើយខ្ញុំដឹងថាខ្ញុំអាចធ្វើបាន...

ចំពោះបេក្ខជនប្រធានាធិបតីលើកនេះ មានគេយល់ឃើញមានការឃោសនា"គំនិតអវិជ្ជមាន"ជារច្រើន តើមានប៉ះពាល់ដល់ទស្សនៈលោកដែរឬទេ?ខ្ញុំមិនអាចសម្រេចចិត្តបោះឆ្នោតឱ្យនរណាម្នាក់ ដោយសារតែខ្ញុំជាសមាជិកគណបក្សសាធារណរដ្ឋនោះទេ ខ្ញុំត្រូវស្តាប់ការជជែកទល់មុខគ្នារបស់បេក្ខជនទាំង២ឱ្យបានពាដងសិន ទើបមានអ្វីសម្រាប់ពិចារណាថានរណាប្រសើរជាង? ពេលនោះទើបខ្ញុំសម្រេចចិត្តថានឹងបោះឆ្នោតឱ្យនរណាម្នាក់...សម្រាប់ពេលនេះមិនទាន់ដឹងនៅឡើយទេ...

លោកមានដើមកំណើតជាខ្មែរនៅសង្កាត់១៨នេះមានសហគមន៍ខ្មែរធំជាងគេ តើលោកអំពាវនាវឱ្យ"ខ្មែរបោះឆ្នោតឱ្យលោក"របៀបណា? ខ្ញុំបានដើរឃោសនារាល់ថ្ងៃ គោះទ្វារគេតាមផ្ទះគឺមិនមែនដោយសារតែខ្ញុំជាខ្មែរប៉ុណ្ណោះទេ គឺដោយសារខ្ញុំដឹងថា"ខ្ញុំមានសមត្ថភាព"នឹងជួយឱ្យមានការផ្លាស់ប្តូរក្នុងជីវិតម្នាក់ៗបានដោយអ្នកទាំងនោះ ដើម្បីសេចក្តីត្រូវការឱ្យខ្ញុំជួយ នឹងបានដឹងជាមុនថាជីវិតគេនឹងទៅជាអ្វី? ខ្ញុំសន្យា គឺខ្ញុំនឹងធ្វើបាននេះជាកំណើតរបស់ខ្ញុំជាខ្មែរ...ហេតុនេះហើយដែលខ្ញុំសុំឱ្យបងប្អូនបោះឆ្នោតឱ្យខ្ញុំ... ៕

## តមកទំព័រទី ០៤ ជីវប្រវត្តិ និងទស្សនៈសង្ខេប រ៉ាឌី ម៉ម

លោកមានអ្វីនិយាយទៅអ្នកទាំងនោះដើម្បីឱ្យគេបោះឆ្នោតឱ្យលោកវិញទេ?

ខ្ញុំសូមអរគុណដល់បងប្អូនដែលបានគាំទ្រខ្ញុំរីឯអ្នកដែលមិនសប្បាយចិត្តនឹងដំណើរទៅកម្ពុជារបស់ខ្ញុំ កាលពី២ឆ្នាំមុន ខ្ញុំសូមជម្រាប់ថា ពេលនោះខ្ញុំទៅធ្វើបុណ្យម្តាយខ្ញុំ ក៏ឆ្លៀតពេលទៅជួបមន្ត្រីនយោបាយជាច្រើន មានទាំងមន្ត្រីប្រក្សប្រឆាំងផងដែរ មិនមែនតែលោក ហ៊ុន សែន តែម្នាក់ទេ។ ក្នុងនាមខ្ញុំជាដំណាងរាស្ត្រអាមេរិកាំងម្នាក់ខ្ញុំយល់ថា ខ្ញុំក៏អាចទៅជួបមន្ត្រីនយោបាយកម្ពុជាបានដែរ ពុំមែនទៅបំរើនយោបាយនរណាទេ តែនៅតែបំរើបើកទ្វារដែលលំបាកជូនបងប្អូនណាដែលត្រូវការឱ្យខ្ញុំជួយអ្វីមួយ, នោះក៏ជាតួនាទីដំណាងរាស្ត្របានដែរ។ ខ្ញុំសូមបញ្ជាក់ម្តងទៀតថា ខ្ញុំជាប់ឆ្នោតនៅសង្កាត់១៨ឡូវែលនេះ ខ្ញុំនៅបំរើសង្កាត់នេះ ដោយមិនខ្លាចលំបាកនឿយហត់អ្វីទេ ឱ្យតែបងប្អូនប្រាប់ខ្ញុំមកចុះ ៕

# រំលឹកព្រឹត្តិការណ៍ព័ត៌មានពីថ្ងៃទី០១ មិថុនា ដល់៣១កក្កដា ឆ្នាំ២០១៦

Press Review

**ដោយ ហ្វ្រង់ស្វា ប៉ុងសូ**
**បកប្រែពីភាសាបារាំងដោយខ្មែរផុសស.រ.អា.**
**នយោបាយក្នុងប្រទេស**

**តពីលេខមុន**

**ព្រឹត្តិការណ៍ កែម ឡី**



ហ្វ្រង់ស្វា ប៉ុងសូ

*ថ្ងៃទី១០កក្កដា កែម ឡី, បញ្ញាវន្តខ្មែរដ៏ភ្លឺស្វាងម្នាក់, បានត្រូវគេធ្វើឃាតដោយបាញ់ផ្ទិបនឹងកាំភ្លើងខ្លីចំនួន២គ្រាប់ នៅពេលដែលលោកកំពុងផឹកកាហ្វេនៅកន្លែងចាក់សាំងមួយ, ដូចដែលលោកធ្លាប់ធ្វើជាធម្មតារាល់ពេលព្រឹក។ ប៉ូលិសបានឃាត់ខ្លួនអតីតយោធាបានម្នាក់ភ្លាម (លឿនពេករហូតដល់រកគេជឿមិនបាន),យោធានោះឈ្មោះ អឿត អាង, ហៅ ជួប សម្លាប់, អំអាងថា សម្លាប់ដោយបុព្វហេតុ "បានជំពាក់លុយ ៣000ដុល្លា ហើយមិនសង", ប្រយោគនេះបានផ្សាយភ្លាមដោយ"ក្រុមព័ត៌មានរហ័ស ហ្វ្រេសញូ", ប៉ុន្តែប្រពន្ធរបស់ជននោះបានប្រកែក។ "វាអាក្រក់ណាស់! ឧក្រិដ្ឋកម្មនេះ មានជាប់ទាក់ទងនឹងរឿងនយោបាយ", ឧទ្ទាន មឿង តុលា, ជាមិត្តជិតស្និត នឹងជាអ្នកការពារសិទ្ធមនុស្សដ៏ល្បីម្នាក់។ ម៉ាស៊ីនថត "វីដេអូ"នៅក្នុងបន្ទប់ចាក់សាំងនោះ បានបាត់ យ៉ាងគួរឱ្យសង្ស័យ... មានរូប"វីដេអ"មួយទៀត ថតដោយទូរស័ព្ទដៃឯកជន បង្ហាញរូបថា ជនសង្ស័យថាជាឃាតករបានឡើងជិះម៉ូតូប៉ូលិស, ហាក់ដូចជាមានសេរីភាពខ្លាំងណាស់។ យុវជន២នាក់ទៀត ដែលមកផឹកកាហ្វេជាមួយ កែម ឡី ២ថ្ងៃមុន, បានសម្គាល់មនុស្ស៣នាក់ ដែលលបមើលពួកគេដ៏គួរឱ្យសង្ស័យ។ បារម្ភណ៏ថាអាចនឹងមានគ្រោះថ្នាក់ ពួកគេរត់ទៅប្រទេសថៃ ហើយសុំសិទ្ធិជាជនជ្រកកោននយោបាយ"CD du 15.07.16"។

*នៅលើទំព័រ"ហ្វេសប៊ុក", នៅប៉ុន្មានម៉ោងក្រោយមក, ហ៊ុន សែន បានធ្វើការថ្កោលទោសយ៉ាងទន់ជ្រាយលើឃាតកម្មនោះ។ ក្រុមប្រព័ន្ធផ្សព្វផ្សាយរដ្ឋាភិបាល(មានទាំង"ហ្វេស្រញូ"ផង) បានចោទប្រកាន់ កឹម សុខា ថាបានធ្វើឱ្យ កែម ឡី ត្រូវគេសម្លាប់ដោយក្បត់គ្នា(!!!)។ សម រង្ស៊ី សរសេរថា"គេបន្ថែមការប្រមាថ ពីលើការរងរបួស"។ អ្នកនាំពាក្យរដ្ឋាភិបាលថ្លែងថា "រាជរដ្ឋាភិបាល នឹងបក្សកាន់អំណាចមានការសោកស្ដាយចំពោះឃាតកម្មលើលោក កែម ឡី" (CD du 13.07.16)។ រំលឹកដល់ពីឃាតកម្មបន្ទាប់ពីថ្ងៃទី៣០មិនា១៩៩៧(មានស្លាប់១៦នាក់, របួសជាង៤៦នាក់), ឃាតកម្មលើ ជា វិជ្ជា ថ្ងៃ២៤មករា ២00៤, ឃាតកម្មលើ ឈុត វុទ្ធី ឆ្នាំ២០១២, មិនដែលរកឃើញឃាតករទេ គ្មាននរណាជឿសម្ដីរដ្ឋាភិបាលទៀតទេ ហើយពាក្យចចាមអារាមរបស់រាស្ត្របានចោទប្រកាន់ដោយគ្មានញញើតថា ជាស្នាដៃរដ្ឋាភិបាល។ នាយកអង្គការ "លីកាដូ" បង្ហាក់ថា"បើគ្មានការស៊ើបអង្កេតឯករាជ្យ នឹងគ្មានប្រើមធ្យោបាយឯកទេសអន្តរជាតិទេនោះ គឺគ្មានរកយុត្តិធម៌ឱ្យគាត់ទេ"(CD du 12.07.16)។

*កែម ឡី មានបុព្វហេតុគ្រប់គ្រាន់ ដែលធ្វើឱ្យគេចង់បំបាត់រូបគាត់ៈ លោកទើបនឹងបញ្ចេញយោបល់នៅលើសេចក្ដីរាយការណ៍របស់"គ្លោបូលវិតណេស", គឺជាសេចក្ដីថ្លែងធ្វើប្រឆាំងនឹងគ្រួសារលោក ហ៊ុន សែន ដោយចំពោះ, ដូចដែលធ្លាប់ធ្វើសព្វមួយដង។ កែម ឡី បានសិក្សាយ៉ាងល្អិតល្អន់ពីឯកសារ ហើយបកស្រាយនៅលើ "វិទ្យុអាស៊ីសេរី"។ ថានឹងចោទប្រកាន់ពិការផ្ដល់ឯកសារទៅសមាគម... កែម ឡី បានធ្វើកិច្ចប្រជុំសាធារណនៅតាមភូមិ ៥ដង ហើយ ក្នុងចំណោម១00 ដែលបានគ្រោងទុក, លោកបានធ្វើឱ្យមានចលាចលក្នុងពពួកអ្នកមានអំណាច, លោកបានផ្ដើមបញ្ចេញកំណាព្យ១៩ឃុត នៅក្នុងនោះលោកមានយកសមាជិកអ្នកមានអំណាចខ្លះជាតុ្លកកំប្លែង...

*មនុស្សរាប់ពាន់នាក់ មកគោរពសពលោក កែម ឡី ដំកល់នៅវត្តជ្រោយចង្វារ ជំនួន២សប្ដាហ៍, បន្ទាប់មកមនុស្សពី៥0ម៉ឺនដល់ ១លាន៥សែននាក់ បើតាមការប៉ាន់ស្មាន(១0%នៃប្រជាពលរដ្ឋ) បានតាមដង្ហែរសពរហូតដល់ត្រាំកក់(ខេត្តតាកែវ) ដែលស្ថិតនៅ៧0គ.ម.ពីភ្នំពេញ។ គឺជាការប្រមូលប្រជាពលរដ្ឋដ៏ធំបង្អស់ចាប់តាំងពីពិធីបូជាព្រះសពព្រះករុណានរោត្តម សីហនុ មក, ក៏ប៉ុន្តែគ្មានទូរទស្សន៏, ទាំងអស់ជារបស់រដ្ឋ, គ្មាននរណាមួយផ្សព្វផ្សាយទេ... បើតាមសម្ដីរដ្ឋាភិបាល គឺមានតែប៉ុន្មានរយនាក់តែប៉ុណ្ណោះ ដែលដង្ហែរក្បួនសព...ទាំងអស់បានប្រព្រឹត្តទៅដោយស្ងាត់ស្ងៀម បើទោះជាមានចល័តរថក្រោះក៏ដោយ (បើតាមរដ្ឋាភិបាល គឺយកទៅជួសជុល), ចំណែកឯកងទ័ពចល័តមកពីខេត្តចូលក្នុងរាជធានី(តាមផ្លូវការណ៍ គឺជាការចល័តជាធម្មតា), ជាន់គ្នាអីក៏ល្មម្លេះ?

*ថ្ងៃទី១សីហា ហ៊ុន សែន បានប្ដឹងព្រឹទ្ធសមាជិក ថាច់ ឡានី នឹង សម រង្ស៊ី ដែលបានចោទលោកថា "ជាអ្នកទទួលខុសត្រូវលើការស្លាប់របស់កែម ឡី(CD du 02.08.16)។

*ទាំងអស់គ្នាយល់ស្របដើម្បីនិយាយថា គឺជាមនុស្សសំខាន់សម្រាប់អនាគតបានបាត់បងទៅហើយ "គឺជាសម្លេងនៃវិចារណញ្ញាណដ៏តិចតួចបង្អើរតាមវិទ្យុដែលចេះបង្ហាញពីការមិនពេញចិត្តកាន់តែកើនឡើង ប្រឆាំងប្រព័ន្ធនយោបាយដែលចង់តែឈ្នះនឹងឃោឃៅ, ពុករលួយនឹងមិនទទួលខុសត្រូវ..." (CD du 12.07.16)។ រនាំងនៃទុក្ខព្រួយបានធ្លាក់មកគ្របដណ្ដប់លើប្រទេស៕

**(នៅមានត)**


យើងខ្ញុំយកចិត្តទុកដាក់ដើម្បីឲ្យលោកអ្នកញញឹម។
*លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់!*





លោកអ្នកទទួលបានអត្ថប្រយោជន៍ទាំងអស់របស់លោកអ្នកនៅក្នុងកម្មវិធីស្តង់ដារ MassHealth និងកម្មវិធី Medicare រួមទាំងសេវាកម្មជាច្រើនទៀត។

- លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យ ដោយមិនបង់ប្រាក់ ដែលរួមមាន៖*
  - ពិគ្រោះយោបល់នៅការិយាល័យ និងសម្អាតធ្មេញ
  - ដាក់ក្រាសធ្មេញទាំងមូលនិងដោយផ្នែក
  - ប៉ះធ្មេញ
  - ដាំធ្មេញ
- ចំណាយបដិភាគ $0 សម្រាប់គ្រប់សេវាកម្ម
- ប័ណ្ណ លោកអ្នកមានសុខភាពល្អ សម្រាប់ទិញទំនិញពាក់ព័ន្ធនឹងសុខភាពដែលមិនមានវេជ្ជបញ្ជា (រហូតដល់ $140ក្នុងមួយឆ្នាំ / $35 ក្នុងមួយត្រីមាស)*
- សេវាកម្មដឹកសមាជិកទៅកាន់និងមកពីកន្លែងណាត់ជួប*
- អាចហៅទូរស័ព្ទទៅកាន់សមាជិកក្រុមការងារនៃគម្រោង SWH បាន 24/7

SWH SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅ:
1-888-566-3526(ខ្សែទូរស័ព្ទឥតគិតថ្លៃ) TTY/TDD:711
www.seniorwholehealth.com/SNP
យើងខ្ញុំបើកដំណើរការចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ ប្រាំពីរ (7) ថ្ងៃក្នុងមួយសប្ដាហ៍។

ប្រសិនបើលោកអ្នកមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធីស្តង់ដារ MassHealth ក៏ប៉ុន្តែមិនមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធី Medicare ផ្នែក A និង/ឬក៏ផ្នែក B លោកអ្នកប្រហែលជា អាចចុះឈ្មោះនៅក្នុងកម្មវិធីជម្រើសថែទាំសុខភាពមនុស្សចាស់ MassHealth Senior Care Options (SCO) របស់យើងខ្ញុំបាន។
លោកអ្នកដែលឆ្លើយតបទៅនឹងលក្ខខណ្ឌខាងលើអាចចុះឈ្មោះបានគ្រប់ពេលវេលារៀងរាល់ឆ្នាំ។

* *លក្ខខណ្ឌកំណត់អាចត្រូវបានអនុវត្ត*

គម្រោងសុខភាពទាំងមូលរបស់មនុស្សចាស់ គឺជាគម្រោងថែទាំសុខភាព HMO SNP ដែលមានការសម្របសម្រួល និងកិច្ចសន្យាផ្តល់- ទទួលសេវាកម្មនៃកម្មវិធី Medicare និងកិច្ចសន្យាជាមួយ Commonwealth of Massachusetts/កម្មវិធី EOHHS MassHealth។ ការចុះឈ្មោះធ្វើឡើងដោយស្ម័គ្រចិត្ត និងអាស្រ័យទៅលើការបន្តកិច្ចសន្យាប្រចាំឆ្នាំ។ ព័ត៌មានអំពីអត្ថប្រយោជន៍នៅក្នុងឯកសារនេះ គឺជាសេចក្តីសង្ខេបមួយ មិនមែនជាសេចក្តីពិពណ៌នាលម្អិតអំពីអត្ថប្រយោជន៍ទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យគម្រោង។ លក្ខខណ្ឌកំណត់ ប្រាក់បដិភាគ ឬក៏លក្ខខណ្ឌកម្រិតផ្សេងៗទៀតអាចត្រូវបានអនុវត្ត។អត្ថប្រយោជន៍ រូបមន្ត បណ្តាញអ្នកផ្តល់សេវាកម្ម និងបណ្តាញឱសថស្ថាន អាចត្រូវបានផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករា នៃឆ្នាំនីមួយៗ។ លោកអ្នកត្រូវតែបន្តបង់បុព្វលាភផ្នែក B របស់លោកអ្នក ប្រសិនបើបុព្វលាភនោះមិនកំពុងត្រូវបានបង់ដោយភាគីណាមួយផ្សេងទៀតនៅឡើយទេ។ គម្រោងនេះត្រូវបានបង្កើតឡើងសម្រាប់មនុស្សដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានជំនួយវេជ្ជសាស្ត្រដែលទទួលបានទាំងពីរដ្ឋ និងកម្មវិធី Medicare។
H2224_2015_104kh Accepted 12/7/2014

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed**
**for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

ឌឺ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឺ ខេមបូឌា ដេលី

# អ្នកនយោបាយអាមេរិកក្នុងរឿងក្តីឆបោក នៅកម្ពុជាធ្វើអត្តឃាត

**ដោយ ឃួន ណារិម | ថ្ងៃច័ន្ទ ទី១២ខែកញ្ញា ឆ្នាំ២០១៦**

សមាជិកសភាប្រចាំរដ្ឋញូយ៉កម្នាក់ដែលស្ថិត



ក្នុងចំណោមចុងចោទក្នុងរឿងក្តីឆបោកដ៏ធំមួយនៅតុលាការក្រុងភ្នំពេញបានបាញ់សម្លាប់ខ្លួន ឯងកាលពីថ្ងៃសុក្រនៅទីកប់ខ្មោចក្នុងក្រុងរ៉ូឆេស្ទឺជាផ្នែកមួយនៃមណ្ឌលរបស់លោកក្នុងក្រុងញូយ៉កភាគខាងជើង។

លោក វីល្លៀម ណូចេ (William Nojay) អាយុ៥៩ឆ្នាំ ក៏ជាពិធីករកម្មវិធីវិទ្យុ មេធាវី សហគ្រិន និងជាឪពុករបស់កូនបីនាក់ ស្ថិតក្នុងចំណោមបុរសបួននាក់ដែលប្តឹងដោយពេទ្យធ្មេញនៅក្រុងភ្នំពេញពីបទឆបោក បន្ទាប់ពីលោកស្រីបានដាក់ប្រាក់វិនិយោគមួយលានដុល្លារក្នុងក្រុមហ៊ុនកសិកម្មមួយដែលមិនដែលបានចាប់ផ្តើមដំណើរការសោះ។

ចុងចោទផ្សេងទៀតមាន លោក ស៊ីចាន់ ស៊ីវ អតីតឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំអង្គការសហប្រជាជាតិ លោក រិច្ឆឺ សាន (Richer San) អ្នកជំនួញខ្មែរសញ្ជាតិអាមេរិកនៅរដ្ឋកាលីហ្វ័រញ៉ា និង លោក ថូម៉ាស វីលឹម (Thomas Willems) អ្នកជំនួញមកពីរដ្ឋតិចសាស។

ក្រុមហ៊ុន អាក្រា (Akra Agriculture Partners) ជាក្រុមហ៊ុនដើមហេតុនៃរឿងក្តីនេះ មានបំណងលើកកម្ពស់ជីវភាពកសិករកម្ពុជាដោយបង្កើនផលិតកម្មនិងបើកទីផ្សារថ្មីៗ។

យោងតាមក្រុមមេធាវីការពារក្តីរបស់លោកស្រី អេង លីគង់ ជាវេជ្ជបណ្ឌិតដែលអះអាងថាលោកស្រីត្រូវបានគេឆបោកនោះ ទោះជាការជាប់ពាក់ព័ន្ធរបស់លោកក្នុងក្រុមហ៊ុននេះនៅមិនច្បាស់ក៏ដោយក៏ឈ្មោះរបស់លោក វីល្លៀម ណូចេ បាន លេច

តទៅទំព័រទី ២០

Continued from page 01

## US POLITICIAN IN CAMBODIAN FRAUD...

American businessman in California; and Thomas Willems, a businessman from Texas. Akra Agriculture Partners, the firm at the center of the case, was meant to lift up Cambodia's farmers by boosting production and opening new markets.

Though his involvement in the firm remains somewhat unclear, William Nojay's name appeared on some of the company's accounts, according to lawyers for EngLy kuong, the dentist who claims she was defrauded.

The politician had previously dismissed claims of any wrongdoing in the case, and said he was simply caught up in a personal dispute between Ms. Lykuong and Mr. San.

According to the Democrat and Chronicle, a newspaper in Rochester, the case in Cambodia was among a number of legal problems facing the politician, who was up for re-election later this month. In its extensive reporting on his suicide, the newspaper said his problems in Cambodia were not his most pressing concern.

William Nojay was facing criminal prosecution for charges related to the alleged disappearance of funds from an account he managed for a longtime legal client and friend, architect Carlton DeWolff, a partner in a project to modernize a city school, sources told the newspaper.

"I'm still in shock," Mr. DeWolff told the newspaper on Friday. "He was always an upstanding person. He always treated me good up until this Jordan thing," he added, referring to the criminal case.

Michael Caputo, director of Donald Trump's New York state Republican primary campaign, told the Democrat and Chronicle that William Nojay was "as conservative as they come, a reliable voice for those values against the greatest odds."

"And he was indefatigable, which makes this news even more shocking," he was quoted as saying.

The grief was not shared by Ms. Lykuong and her family.

"Dr. Lykuong got her justice. One of the cheaters accepted his fraud," the dentist's brother, EngLykhoing, wrote in a post to Facebook along with a news article about the suicide. "He sentenced himself without disturbing the court. R.I.P."

Ms. Lykuong said yesterday that her lawyer in the U.S. had been hounding William Nojay in recent months, but that he refused to cooperate.

"I think it is a good thing to show the court that they really cheated me," she said of the suicide.

The trial is set to continue at the municipal court on September 27, according to Ms. Lykuong's lawyer, Orn Hing.

# រដ្ឋមន្ត្រីប្រាប់ UN ថា ការឱ្យប្រកាន់តាម លទ្ធិប្រជាធិបតេយ្យល្អឥតខ្ចោះ មិនសមហេតុសមផល

**ដោយ ខូលីន ម៉ីយន៍ | ថ្ងៃច័ន្ទ ទី២៦ ខែកញ្ញា ឆ្នាំ២០១៦**

លោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេសបាននិយាយការពាររដ្ឋាភិបាលចំពោះមុខមហាសន្និបាតអង្គការសហប្រជាជាតិនៅក្នុងទីក្រុងញូវយ៉ក កាលពីថ្ងៃសៅរ៍ ដោយលើកឡើងថាគណបក្សកាន់អំណាចត្រូវបានគេតម្រូវឱ្យប្រកាន់តាម "លទ្ធិប្រជាធិបតេយ្យល្អឥតខ្ចោះ" ដោយមិនសមហេតុសមផលខណៈគណបក្សប្រឆាំង"កំពុងប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ"។

ពេលថ្លែងសុន្ទរកថាដ៏សំខាន់លើកដំបូងទៅកាន់អង្គការសហប្រជាជាតិរដ្ឋមន្ត្រីក្រសួងការ



លោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេសថ្លែងអំឡុងសម័យប្រជុំលើកទី៧១របស់មហាសន្និបាតអង្គការសហប្រជាជាតិកាលពីថ្ងៃសៅរ៍ ក្នុងទីក្រុងញូវយ៉ក។ រូបថត: UN Photo Cia Pak

បរទេសថ្មីរូបនេះគឺជាមន្ត្រីរដ្ឋាភិបាលចុងក្រោយបំផុតដែលវាយបកលើការអះអាងដែលថា គណបក្សប្រជាជនកម្ពុជាកំពុងព្យាយាមបំបាក់គណបក្សប្រឆាំង និងអ្នករិះគន់ផ្សេងៗទៀតមុនការបោះឆ្នោតឃុំ-សង្កាត់នៅឆ្នាំក្រោយ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅឆ្នាំ២០១៨។

លោកបានមានប្រសាសន៍ថា "ស្ថាប័នអន្តរជាតិ និងសមាជិកសភាលោកខាងលិចជួនកាលបានចោទប្រកាន់ និងព្យាយាមដាក់ការស្តីបន្ទោស។ ខ្ញុំនៅទីនេះចំពោះមុខអស់លោកមិនមែនក្នុងនាមជាគណបក្សដែលត្រូវបានចោទប្រកាន់ទេ ខ្ញុំនិយាយទៅកាន់អស់លោកក្នុងនាមជាប្រទេសដែលតែងតែត្រូវបានវិនិច្ឆ័យក្នុងផ្លូវអវិជ្ជមានហើយថែមទាំងតែងតែត្រូវបានគេយល់ខុស និងមិន

ទទួលស្គាល់ទៀតផងជាពិសេសនៅលោក

តទៅទំព័រទី ២០

## MINISTER TELLS UN 'PERFECT DEMOCRACY' NOT REALISTIC

**byColin Meyn | September 26, 2016**

Foreign Minister PrakSokhonn defended the government before the U.N. General Assembly in New York on Saturday, saying that the ruling party was being held to unrealistic expectations of a "perfect democracy" while the opposition was "committing very serious crimes."

Delivering his first major address to the U.N., the new foreign minister was the latest government official to hit back at claims that the CPP is attempting to cripple the opposition and other critics ahead of local elections next year and national elections in 2018.

"International institutions and Western parliamentarians have pointed the finger sometimes and tried to lay blame. I am here before you not as an accused party; I am speaking to you as a country that is often judged negatively, and even more often it is misunderstood and not recognized, particularly in the Western world," he said.

"In the West, some NGOs, some media and some governments often describe our weaknesses as crimes of the state," Mr. Sokhonn said, lamenting the democratic standards outlined in the 1991 Paris Peace Agreements.

"With the Paris Agreements, we have been asked to accept a perfect model of democracy, and this does not take into account the fact that some other countries have a different approach. We often find ourselves in a situation in which our opposition is committing very serious crimes," he said.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ប្រព័ន្ធបោះឆ្នោតបរាជ័យចាត់ចំណាត់ថ្នាក់កម្ពុជាថាអាក្រក់ជាងគេក្នុងតំបន់

**ដោយ ឆន ភារុណ និង Michael Dickison | ថ្ងៃសៅរ៍ ទី២៤ ខែកញ្ញា ឆ្នាំ២០១៦**

ការសិក្សាដែលធ្វើបច្ចុប្បន្នភាពដែលចាត់ចំណាត់ថ្នាក់ប្រទេសនានាដោយផ្អែកលើភាពត្រឹមត្រូវនៃការបោះឆ្នោតរបស់គេបានចាត់ថ្នាក់ការបោះឆ្នោតនាឆ្នាំ២០១៣ ដែលបរាជ័យរបស់ប្រទេសកម្ពុជាទៅក្នុងលំដាប់បាតក្រោមរបស់ខ្លួនដោយចាត់ក្នុងជំពូកអាក្រក់បំផុតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងក្នុងចំណោមប្រទេស១០បាតក្រោមគេក្នុងពិភពលោក។

ការបង្ក្រាបបក្សប្រឆាំងការប្រើល្បិចបន្លំលើការចុះឈ្មោះអ្នកបោះឆ្នោតនិងការប្រើហិរញ្ញវត្ថុលើយុទ្ធនាការដោយមិនត្រឹមត្រូវដែលជាការរិះគន់ធម្មតាលើការបោះឆ្នោតជាតិចុងក្រោយរបស់ប្រទេសកម្ពុជាគឺជាអ្វីដែលបន្ទច់បង្អាក់ដ៏សំខាន់ក្នុងការសិក្សាដោយគម្រោងសុចរិតភាពបោះឆ្នោតដែលធ្វើឡើងដោយសាកលវិទ្យាល័យហាវើត និងសាកលវិទ្យាល័យស៊ីដនី។

អ្នកស្រី ផិពប៉ា នរិស អ្នកស្រាវជ្រាវជាសាស្ត្រាចារ្យ និងជាប្រធានគម្រោងរៀបរាប់អំពីអត្ថាធិបតេយ្យការបោះឆ្នោតថា ជារឿងមួយដែលរៀបចំការបោះឆ្នោតដើម្បីធ្វើឱ្យស្របច្បាប់ដល់រដ្ឋាភិបាលប៉ុណ្ណោះ ប៉ុន្តែគេអាចប្រើល្បិចបន្លំលទ្ធផល"។

អ្នកស្រីបាននិយាយក្នុងកិច្ចសម្ភាសអាត់សំឡេងដែលបង្ហោះតាមអ៊ីនធឺណិតដោយសាកលវិទ្យាល័យនៅដើមឆ្នាំនេះថា "បើអ្នកជាមេដឹកនាំផ្តាច់ការដែលគិតអំពីរឿងនេះ វិធីស្រួលបំផុត គឺត្រូវប្រាកដថាគូប្រឆាំងរបស់អ្នកមិនអាចអនុញ្ញាតឱ្យឈរឈ្មោះបានទេ"។

អ្នកស្រីបាននិយាយថា "ការបំបិទសំឡេងអ្នកប្រឆាំងដោយចាប់ពួកគេដាក់ពន្ធនាគារ "ពីបទចោទប្រកាន់ដែលប្រឌិតឡើង"ជាឧទាហរណ៍ គឺ"មានប្រសិទ្ធភាព...ច្រើនជាងដាក់សន្លឹកឆ្នោតបន្លំចូលប្រអប់ឆ្នោតទៅទៀត ហើយជារឿងដែលបង្ហាញឱ្យឃើញច្បាស់ថែមទៀតអ៊ីចឹង"។

នៅកម្ពុជា គណបក្សប្រជាជនកម្ពុជាកាន់អំណាចត្រូវបានចោទថាផ្តន្ទាទោសនិងដាក់ពន្ធនាគារចំពោះមន្ត្រីបក្សប្រឆាំងតាមរយៈបទចោទប្រកាន់ជារឿងនយោបាយដែលរួមមានលោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ និងលោក កឹម សុខា អនុប្រធាន។ លោក រង្ស៊ី កំពុងស្ថិតនៅក្នុងប្រទេសបារាំង ដើម្បីគេចពីការជាប់ពន្ធនាគារចំណែកឯលោក សុខា កំពុងសម្ងំនៅក្នុងទីស្នាក់ការបក្សក្នុងក្រុងភ្នំពេញ។

គម្រោងបោះឆ្នោតដែលចាប់ផ្តើមធ្វើក្នុងឆ្នាំ២០១២បានចាត់ថ្នាក់ភាពត្រឹមត្រូវនៃការបោះឆ្នោតនៅក្នុងប្រទេសចំនួន១៥៣ប្រទេសហើយមកដល់ពេលនេះ។

ការបោះឆ្នោតនាឆ្នាំ២០១៣របស់ប្រទេសកម្ពុជាដែលចាត់ទុកដោយគម្រោងថា "បរាជ័យ" គឺមានចំណាត់ថ្នាក់ក្នុង១០ប្រទេសបាតក្រោមគេក្នុងពិភពលោក និងអាក្រក់បំផុតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកដែលកាន់តែអាក្រក់ជាងរដ្ឋកុម្មុយនិស្តឯកបក្សដូចជាប្រទេសឡាវ និងវៀតណាមទៅទៀត។

កម្ពុជាមាននីតិវិធីបោះឆ្នោតមិនមានដំណើរការច្រើនជាងប្រទេសទាំងនោះ ហើយទទួលរងគ្រោះពីអ្វីដែលអ្នកស្រី នរិស ចាត់ទុកថា ជាឧបសគ្គធំៗបំផុតពីរចំពោះការបោះឆ្នោតដោយត្រឹមត្រូវ គឺការគ្រប់គ្រងរបស់បក្សកាន់អំណាចទៅលើទូរទស្សន៍ និងការប្រើហិរញ្ញវត្ថុក្នុងយុទ្ធនាការដោយមិនស្មើភាពគ្នា និងពុករលួយ។

អ្នកសង្កេតការណ៍និយាយថា ឧបសគ្គទាំងពីរនេះនៅតែមិនមានការដោះស្រាយនៅឡើយទេមុនការបោះឆ្នោតឃុំសង្កាត់នៅឆ្នាំក្រោយ និងការបោះឆ្នោតជាតិក្នុងឆ្នាំ២០១៨។



ស្ត្រីម្នាក់បោះឆ្នោតអំឡុងពេលការបោះឆ្នោតជាតិនាឆ្នាំ២០១៣។ រូបថត ស៊ីវ ចាន់ណា

លោក គល់ បញ្ញា នាយកប្រតិបត្តិអង្គការខុមហ្វ្រែលបានយល់ស្របនឹងការវាយតម្លៃរបស់គម្រោងនេះ ដោយនិយាយថា គណបក្សប្រជាជនកម្ពុជាជាប្រវត្តិសាស្ត្រប្រើថវិកាក្នុងយុទ្ធនាការរបស់ខ្លួនដោយប្រើប្រាស់ធនធានរដ្ឋដោយយកប្រៀបដាច់លើបក្សប្រឆាំង។

លោក បញ្ញា បាននិយាយថា "គណបក្សប្រជាជនកម្ពុជាប្រើមិនត្រឹមតែហិរញ្ញវត្ថុច្រើន សម្បើមរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រើធនធានរដ្ឋច្រើនលើសលុប ដើម្បីប្រយោជន៍របស់ខ្លួន ដូចជាកម្លាំងប្រដាប់អាវុធរថយន្តអគាររដ្ឋ និងថវិកាជាតិជាដើម"។

លោកបាននិយាយថា "មានការបំភិតបំភ័យការប្រកួតប្រជែងមិនត្រឹមត្រូវ ជម្លោះដែលមិនទាន់ដោះស្រាយចេញ...។ មានការប្រើកម្លាំងប្រដាប់អាវុធ ដើម្បីបំបិទសេរីភាពនៃការបញ្ចេញមតិរបស់បក្សប្រឆាំង។ មានគម្លាតធំរវាងប្រព័ន្ធផ្សព្វផ្សាយក្នុងយុទ្ធនាការបក្សនានា និងការប្រើហិរញ្ញវត្ថុក្នុងយុទ្ធនាការ"។

ដូចគ្នានេះដែរ លោក យឹម សុវណ្ណ អ្នកនាំ

**តទៅទំព័រទី ១៧**

# 'Failed' Electoral System Ranked Asia's Worst

**BY CHHORN PHEARUN AND MICHAEL DICKISON | SEPTEMBER 24, 2016**

An updated study that categorizes countries based on the fairness of their elections has placed Cambodia's "failed" 2013 poll firmly in its bottom tier, ranking it the worst in the Asia-Pacific region and among the bottom 10 in the world.

Stifling of the opposition, manipulation of voter registration and unfair campaign financing—common criticisms of Cambodia's last national election—are key chokepoints in the study by the Electoral Integrity Project, based out of Harvard University and the University of Sydney.

Researcher Pippa Norris, a Harvard lecturer and the project's head, describes an electoral autocracy as one in which "having elections legitimizes the government, but they can manipulate the -result."

"If you're a dictator thinking about this, the easiest way is to make sure your opponent is in some way not allowed to stand," Norris says in a recorded interview posted online by the university earlier this year.

Silencing opposition voices by imprisoning them "on basically trumped up charges" for example, is "much more effective…than to stuff ballots and more overt things like that," she says.

In Cambodia, the ruling CPP is accused of prosecuting and imprisoning opposition figures through politically motivated charg-es, including CNRP President Sam Rainsy and Vice President Kem Sokha. Mr. Rainsy is in France to avoid prison; Mr. Sokha is in hiding at the party's Phnom Penh headquarters to avoid -arrest.

The electoral project has ranked the fairness of elections in 153 countries, going back to 2012. Cambodia's 2013 election, broadly categorized by the project as "failed," ranks in the bottom 10 in the world and worst in the the Asia-Pacific region—faring worse, even, than one-party communist states such as Laos and Vietnam.

Cambodia has more dysfunctional electoral procedures than such states, and suffers from what Ms. Norris describes as two of the biggest obstacles to fair elections: ruling-party control over television broadcasts, and unequal and corrupt campaign financing.

Both of these issues remain unaddressed ahead of Cambodia's upcoming commune elections next year and general election in 2018, observers say.

Koul Panha, executive director of the Committee for Free and Fair Elections in Cambodia, or Comfrel, endorsed the project's assessment, saying the CPP has historically filled its campaign war chest with an assortment of state resources, putting the opposition at a gross disadvantage.

"The CPP uses not only a huge amount of its own finances, but also an excessive use of state resources for its own gain, such as armed forces, vehicles, state buildings and the national budget," Mr. Panha said.

"There's intimidation, unfair competition, unresolved disputes …. There has been the use of armed forces to suppress the opposition's freedom of expression," he said. "There's a big gap between the parties' campaign media and campaign finances."

**Continued to Page 15**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# អ.ស.ប សិទ្ធិមនុស្សប្រចាំកម្ពុជាប្រតិកម្មចំពោះការសម្រេចផ្តន្ទាទោសលើ លោក នី ចរិយា

អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ប្រតិកម្មចំពោះការសម្រេចផ្តន្ទាទោសលើលោក នី ចរិយា អគ្គលេខាធិការរង គ.ជ.ប ដោយចោទថា តុលាការពុំបានបង្ហាញភស្តុតាងគ្រប់គ្រាន់សម្រាប់ការចោទប្រកាន់លោក នី ចរិយា នោះឡើយ។ បញ្ហានេះ អង្គការសហប្រជាជាតិយល់ថា ជានិន្នាការមួយគួរឱ្យបារម្ភពាក់ព័ន្ធនិងការប្រើច្បាប់ប្រឆាំងសំឡេងឯករាជ្យ។

អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាស្នើឱ្យកម្ពុជាធ្វើកំណែទម្រង់ក្រមព្រហ្មទណ្ឌ។

មន្ត្រីតំណាងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ហៅកាត់ថា យូអេន អូអេច្ចស៊ីអេច្ចអ (UN OHCHR -Cambodia) អ្នកស្រី វ៉ាន់ហ៊ី លី (Wan Hea Lee) បានឆ្លើយតាមប្រព័ន្ធអេឡិចត្រូនិក ឬអ៊ីម៉ែលថា ដោយសារតែសេរីភាពសម្តែងមតិរាប់បញ្ចូលទាំងសិទ្ធិក្នុងការសម្តែងមតិលើការសម្រេចរបស់តុលាការនោះ មូលដ្ឋាននៃការផ្តន្ទាទោសលើលោក នី ចរិយា ដោយហេតុតែលោកមិនពេញចិត្តចំពោះការសម្រេចរបស់តុលាការ ហើយដែលរហូតដល់តុលាការគិតថាជាករណីបរិហារកេរ្តិ៍បរិហារបង្កាច់កេរ្តិ៍ និងប្រើប្រាស់ឥទ្ធិពលដាក់សម្ពាធលើតុលាការខេត្តសៀមរាបនោះ គឺវាផ្ទុយទៅនឹងច្បាប់សិទ្ធិមនុស្ស។

អ្នកស្រីបន្តទៀតថា ការកាត់ទោសដោយគ្មានភស្តុតាង ឬមិនមានហេតុផលផ្លូវច្បាប់ច្បាស់លាស់គឺជាហេតុផលចម្បងដែលធ្វើឱ្យប្រព័ន្ធតុលាការបាត់តម្លៃ។ ករណីនេះ រឹតតែធ្វើឱ្យកេរ្តិ៍ឈ្មោះតុលាការអាក្រក់ថែមទៀត ហើយក៏បង្ហាញដែរថា ហេតុអ្វីបានជាត្រូវធ្វើកំណែទម្រង់ប្រព័ន្ធតុលាការជាបន្ទាន់នោះ។

កាលពីថ្ងៃទី២២ កញ្ញា ចៅក្រមជំនុំជម្រះនៃតុលាការក្រុងភ្នំពេញលោក ឃី ឆៃ បានសម្រេចផ្តន្ទាទោសលោក នី ចរិយា អគ្គលេខាធិការរង គ.ជ.ប និងជាអតីតប្រធានការិយាល័យស៊ើបអង្កេតសមាគមការពារសិទ្ធិមនុស្សអាដហុក (ADHOC) ដាក់ពន្ធនាគារ៦ខែ និងពិន័យលុយចំនួន៦លានរៀល។

ឆ្លើយតបទៅនឹងប្រតិកម្មរបស់មន្ត្រីអង្គការសហប្រជាជាតិនេះ អ្នកនាំពាក្យក្រសួងយុត្តិធម៌ លោក គឹម សន្តិភាព ថ្លែងថា លោក នី ចរិយា អាចប្តឹងបន្តចំពោះសេចក្តីសម្រេចរបស់តុលាការ។ ការសន្និដ្ឋានរបស់មន្ត្រីអង្គការសហប្រជាជាតិហាក់មិនយល់អំពីប្រព័ន្ធច្បាប់នៅកម្ពុជាៈ គិតថាអង្គការសហប្រជាជាតិគឺជាចំណេះដឹងជ្រៅជ្រះផ្នែកច្បាប់គួរតែយល់ពីប្រព័ន្ធច្បាប់ប្រទេសមួយៗឱ្យបានច្បាស់មុនហ្នឹងធ្វើការផ្តល់យោបល់ឬមួយធ្វើការសន្និដ្ឋានអ្វីមួយ។ ពាក់ព័ន្ធ និងអំណាចតុលាការអង្គការសហប្រជាជាតិក៏គួរដឹងដែរថា អំណាចតុលាការកម្ពុជាយ៉ាងម៉េច។ ការសម្រេចសេចក្តីរបស់ស្ថាប័នឯករាជ្យមួយនេះ គឺជាការសម្រេចសេចក្តីដោយឆន្ទានុសិទ្ធិដែលគ្មានស្ថាប័នណាដែលអាចចោទប្រកាន់ថាអញ្ចេះអញ្ចុះបានទេ។

តុលាការសម្រេចចោទប្រកាន់លោក នី ចរិយា ដោយយោងលើសំណុំរឿងព្រហ្មទណ្ឌ ក្រោមបទចោទបរិហារកេរ្តិ៍បរិហារបង្កាច់កេរ្តិ៍ និងពីបទ



អគ្គលេខាធិការរងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) លោក នី ចរិយា (ស្តាំ) ត្រូវបានប៉ូលិសបញ្ជូនទៅតុលាការកំពូល នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៦។ RFA/Yang Chandara

ប្រើប្រាស់ឥទ្ធិពលដាក់សម្ពាធលើតុលាការខេត្តសៀមរាប។ ករណីនេះ គឺផ្តើមចេញពីជម្លោះដីធ្លីរវាងពលរដ្ឋជាង៣០គ្រួសារនៅឃុំជប់រំដេង ស្រុកស្វាយលើ ខេត្តសៀមរាប ជាមួយក្រុមហ៊ុនវៀតណាមឈ្មោះសហគមន៏តាខ្មៅ។

ដើមបណ្តឹងនៅក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ គឺជាព្រះរាជអាជ្ញារងលោក សុខ កែវបណ្ឌិត និងចៅក្រមជំនុំជម្រះខេត្តសៀមរាបម្នាក់ទៀត លោក គិ រិទ្ធី។ មន្ត្រីតុលាការទាំងពីររូបនេះ សម្រេចចោទប្រកាន់លោក នី ចរិយា ពីបទបរិហារកេរ្តិ៍បន្ទាប់ពីរកឃើញថា លោក នី ចរិយា ធ្វើសន្និសីទកាសែតកាលពីថ្ងៃទី១២ ខែឧសភា និងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៥ នៅការិយាល័យសមាគមអាដហុកខេត្តសៀមរាប និងនៅភ្នំពេញដោយចោទថា មន្ត្រីតុលាការឃុបឃិតជាមួយអាជ្ញាធរប្រព្រឹត្តអំពើពុករលួយ។

ភស្តុតាងតាមបណ្តាញសារព័ត៌មាន គឺជាមូលដ្ឋានដែលមន្ត្រីតុលាការខេត្តសៀមរាបចោទប្រកាន់ថា លោក នី ចរិយា បរិហារកេរ្តិ៍ធ្វើឱ្យប៉ះពាល់ដល់ស្ថាប័នអយ្យការ និងតុលាការជុំវិញសំណុំរឿងដីធ្លីនេះ។ នៅក្នុងបន្ទប់សវនាការ លោក នី ចរិយា បានជម្រាបអង្គជំនុំជម្រះថា សន្និសីទកាសែតទាំងពីរលើកនោះ គឺលោកពុំបាននិយាយពីតុលាការបានប្រព្រឹត្តអំពើពុករលួយឡើយ។

ប៉ុន្តែលោកបានលើកពីការអនុវត្តខុសនីតិវិធីរបស់មន្ត្រីតុលាការខេត្តសៀមរាបទៅវិញទេ។

ថ្វីត្បិតតែមានការផ្តន្ទាទោសបែបនេះ លោក អំ សំអាត មន្ត្រីជាន់ខ្ពស់អង្គការលីកាដូ(LICADHO) មានប្រសាសន៍ថា សាលក្រមដែលបានសម្រេចនេះគឺជាជួង ឬជាសញ្ញាមួយដែលបានគំរាមកំហែងដល់អ្នកការពារសិទ្ធិមនុស្សទាំងឡាយដែលតែងតែរិះគន់ទៅលើប្រព័ន្ធតុលាការ និងរិះគន់ទៅលើភាពអយុត្តិធម៌ទាំងឡាយដើម្បីជួយជនរងគ្រោះ ឬដើម្បីកែលំអប្រព័ន្ធយុត្តិធម៌។ ប៉ុន្តែពុំមានអ្វីគួរឱ្យខ្លាចនោះទេ លោកនៅតែបន្តការងារនេះៈ នេះជាតួនាទីជាភារកិច្ចរបស់យើងបើសិនជាការអនុវត្តន៏មិនត្រឹមត្រូវតាមនីតិវិធីមិនត្រឹមត្រូវតាមច្បាប់យើងត្រូវតែរិះគន់បន្តទៀតដើម្បីធ្វើការស្ថាបនានិងកែតម្រង់ឱ្យប្រព័ន្ធតុលាការឯករាជ្យនិងជាទីទុកចិត្តរបស់ប្រជាពលរដ្ឋយើង។ មិនខ្លាចទោះបីជាមានការចោទប្រកាន់ទាក់ទងបញ្ហានេះក៏ដោយ ពីព្រោះបើសិនជាយើងមិនធ្វើការរិះគន់ទៅលើអ្វីដែលគេធ្វើខុសគឺយើងចូលរួមបន្តឱ្យប្រព័ន្ធនេះដើរផ្លូវខុសទៀតហើយ។

ជុំវិញរឿងក្តីលើលោក នី ចរិយា នេះដែរ សមាគមអាដហុកបានរកឃើញថា ទាំងចៅក្រមលោក គិ រិទ្ធី និងតំណាងអយ្យការខេត្តសៀមរាបលោក សុខ កែវបណ្ឌិត ចាប់ខ្លួន និងចោទប្រកាន់ពលរដ្ឋបំពានច្បាប់ ព្រោះតែតុលាការពុំបានបើកការស៊ើបអង្កេតឱ្យបានច្បាស់លាស់មុននឹងចាប់ខ្លួនពលរដ្ឋ២នាក់ដាក់ពន្ធនាគារ។

ចំពោះការផ្តន្ទាទោសលោក នី ចរិយានេះ គ.ជ.ប អាចនឹងរើសមនុស្សជំនួសលោក នី ចរិយា លុះណាតែសាលក្រមសាលាដំបូងរាជធានីភ្នំពេញចូលជាស្ថាពរ។

អ្នកនាំពាក្យគជប លោក ហង្ស ពុទ្ធា មានប្រសាសន៏ថា គ.ជ.ប នៅរក្សាតួនាទីរបស់លោក នី ចរិយា ជាអគ្គលេខាធិការរងដដែល និងផ្តល់ប្រាក់បៀវត្សរ៏ជាធម្មតាបើសាលក្រមមិនទាន់ចូលជាស្ថាពរនៅឡើយនោះ។ ចំណែកការអវត្តមានលោក នី ចរិយា នៅប៉ុន្មានខែនេះ លោក ហង្ស ពុទ្ធា ថាគឺមិនបានប៉ះពាល់ដល់ដំណើរការការងារ គ.ជ.ប នោះទេ៕

ជ្រើសរើសបុគ្គលិក

**កាសែតខ្មែរផុសស.រ.អាត្រូវការជ្រើសរើសបុគ្គលិកផ្នែកលក់ពាណិជ្ជកម្ម ចំនួន២នាក់**

បេក្ខជនត្រូវមានលក្ខណៈដូចខាងក្រោម :
-រៀននៅមហាវិទ្យាល័យយ៉ាងហោចឆ្នាំទី៣
-មានជំនាញខាងផ្នែក Business ឬ Marketing
-ត្រូវចេះប្រាស្រ័យជាមួយភ្ញៀវពាណិជ្ជកម្មតាមប្រព័ន្ធទូរស័ព្ទ និងជួបផ្ទាល់
-(ត្រូវចេះ Typing), សរសេរ E-mail ប្រើ Internet និង Facebook (បើចេះWebsite កាន់តែល្អ)
-ត្រូវចេះធ្វើការជាមួយសហការីនៅក្នុង Office
-ត្រូវចេះនិយាយ សរសេរភាសាខ្មែរ និងអង់គ្លេស
-ត្រូវការមួយអាទិត្យ១៥ម៉ោង
-ត្រូវមាន License បើកបរ និងរថយន្ត
- Pay មួយម៉ោង $9.30 បូកនឹងរង្វាន់

**សូមទាក់ទងមក សូជាតិ ចាន់ info@khmerpost.us**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ការបញ្ចេញប្រាក់សម្រាប់វិបត្តិស្រូវអង្ករ ជាដំណោះស្រាយមួយគ្រា

**ដោយ ជេនណែល រ៉េតខា និង គុច ណារ៉េន | ថ្ងៃសុក្រ ទី២៣ខែកញ្ញា ឆ្នាំ២០១៦**

ខណៈរដ្ឋាភិបាលខិតខំស្រោចស្រង់វិស័យស្រូវអង្ករដែលទទួលរងផលប៉ះពាល់ដោយសារស្រូវធ្លាក់ថ្លៃ និងការប្រកួតប្រជែងខ្លាំងពីអន្តរជាតិនោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីម្សិលមិញបានសរសើរដល់មន្ត្រីរដ្ឋាភិបាល និង "សប្បុរសជនពាណិជ្ជករ" ដែលធ្វើតាមការអំពាវនាវរបស់លោកដែលស្នើឱ្យមានមូលនិធិជាបន្ទាន់។

ដោយធ្លាក់ចុះពីប្រហែល២៥០ដុល្លារក្នុងមួយតោនកាលពីពាក់កណ្តាលខែសីហាមកនៅត្រឹម១៩៣ដុល្លារក្នុងមួយតោនក្នុងសប្តាហ៍មុននោះ តម្លៃស្រូវដែលម្ចាស់រោងម៉ាស៊ីនកិនស្រូវផ្តល់ឱ្យកសិករបានធ្វើឱ្យវិស័យនេះជួបវិបត្តិរយៈពេលខ្លី ប៉ុន្តែលោកនាយករដ្ឋមន្ត្រីបានប្រកាសកាលពីម្សិលមិញថា វិបត្តិហិរញ្ញវត្ថុដែលអាចកើតមានទប់ស្កាត់បានហើយ។

ដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអនុម័តយល់ព្រមឱ្យមានការបញ្ចេញប្រាក់២៧លានដុល្លារដើម្បីផ្តល់ឧបត្ថម្ភធនដល់ម្ចាស់រោងម៉ាស៊ីនកិនស្រូវដែលជួយឱ្យពួកគេអាចរក្សាលំនឹងនៃតម្លៃស្រូវបាននោះ ការទិញស្រូវបន្ថែមនៅសប្តាហ៍នេះដោយមន្ត្រីរដ្ឋាភិបាល និងមិត្តភក្តិដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភបានជួយវិស័យនេះឱ្យនៅតែមានដំណើរការ។

លោក ហ៊ុន សែន បានមានប្រសាសន៍នៅក្នុងពិធីប្រគល់សញ្ញាបត្រមួយកាលពីម្សិលមិញក្នុងរាជធានីភ្នំពេញថា "ខ្ញុំពិតជាអរគុណជាមួយរដ្ឋមន្ត្រី រដ្ឋលេខាធិការ មន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ ក៏ដូចជាសប្បុរជនពាណិជ្ជកររបស់យើងដែលបានជួយទិញស្រូវ"។

លោកបានបន្ថែមថា "ខ្លះ១០តោន ខ្លះ២០តោនខ្លះ៥តោន។ ឥឡូវមិនមែនជាបញ្ហាគ្មានប្រាក់ទិញស្រូវទេ ប៉ុន្តែជាបញ្ហាមានកន្លែងហាលឬក៏អត់"។

លោក ហ៊ុន សែន បានសង្កត់ធ្ងន់លើចំណុចនេះដោយនិយាយសំដៅដល់លោក អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលទទួលបានស្គាល់ថា លោកបានទិញស្រូវ១០តោន ប៉ុន្តែទុកវានៅរោងម៉ាស៊ីនកិនស្រូវ ។ លោកនាយករដ្ឋមន្ត្រីបានសំដែងការសោកស្តាយចំពោះស្ថានភាពនេះដោយលើកឡើងថា ការចូលរួមចំណែករបស់រដ្ឋមន្ត្រីរូបនេះនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។

លោកបានមានប្រសាសន៍ថា "យើងដោះស្រាយបានតែបញ្ហាប្រាក់ប៉ុណ្ណោះប៉ុន្តែយើងនៅមិនទាន់បានដោះស្រាយបញ្ហាសំខាន់នៅឡើយ



កសិករស្ទូងស្រូវក្បែរចម្ការអំពៅ ក្នុងខេត្តកំពត កាលពីខែកក្កដា។ រូបថត: John Vink

ទេ។ អ្នកទិញស្រូវគ្រប់រូបសូមទិញស្រូវមកហាលនៅផ្ទះខ្លួនឯង" រួចយកវាមកកិននៅភ្នំពេញ។

លោកបានបន្ថែមថា ការធ្វើដូច្នេះវាជួយឱ្យរោងម៉ាស៊ីនស្រូវនៅតាមបណ្តាខេត្តមានកន្លែងទំនេរច្រើនដើម្បីទិញស្រូវ និងកែច្នៃស្រូវ។

ប៉ុន្តែទោះបីជាការខិតខំទាំងនេះក៏ដោយ វានៅមិនទាន់គ្រប់គ្រាន់ដើម្បីដោះស្រាយវិបត្តិ និងបញ្ហាសំខាន់ដែលញាំញីវិស័យស្រូវអង្ករនៅឡើយទេ នេះបើយោងតាមអ្នកជំនាញផ្នែកកសិកម្ម និងអ្នកសេដ្ឋកិច្ច។

លោក ចាន់ សុផល ប្រធានមជ្ឈមណ្ឌលដើម្បីការសិក្សាគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្ពុជាបានលើកឡើងថាអន្តរាគមន៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ទោះបីជាជួបការលំបាកខ្លាំងនៅក្នុងឆ្នាំនេះក៏ដោយតែវាមានសារៈសំខាន់សម្រាប់ជួយដល់វិស័យនេះឱ្យមានដំណើរទៅមុខយូរអង្វែង។

លោកបានលើកឡើងទៀតថា រោងម៉ាស៊ីនកិនស្រូវខ្វះដើមទុនដើម្បីទិញស្រូវពីកសិករ រីឯកសិករវិញមានអារម្មណ៍ខ្លាចជំពាក់បំណុលគេកាន់តែច្រើនឡើងៗឥតឈប់ឈរ និងព្រួយបារម្ភអំពីសុវត្ថិភាពដីធ្លីរបស់ខ្លួន។

**តទៅទំព័រទី ១៩**

# CASH INFLUX A BAND-AID FOR FAILING RICE SECTOR

**By Janelle Retka and KuchNaren | September 23, 2016**

As the government scrambles to buoy a rice sector suffering from crashing paddy prices and fierce international competition, Prime Minister Hun Sen on Thursday lauded the government officials and "generous businesspeople" who heeded calls for emergency funds.

Falling from about $250 per ton in mid-August to $193 last week, the prices that millers were offering farmers for paddy briefly plunged the sector into disarray. But a potential financial calamity has been prevented, the premier announced on Thursday.



Farmers transplant rice next to a sugar cane field in July (John Vink)

With a $27 million grant approved by Mr. Hun Sen to subsidize millers, allowing them to stabilize the price they pay for paddy, additional rice purchases this week by government officials and wealthy friends helped the sector stay operational, he said.

"I'm truly thankful to the ministers, secretaries of state, civil servants and armed forces, as well as the generous business people who have helped purchase paddy," Mr. Hun Sen said at a graduation ceremony in Phnom Penh on Thursday.

"Some have bought 10 tons, 20 tons or five tons," he added. "Now it's not a matter of having no money to buy paddy, but a matter of having a place to dry it."

